ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែមេសា ឆ្នាំ២០១៥

*នៅក្នុងខែមេសា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញការកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖**

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី*

*-បានធ្វើសំណើសុំប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន១៣៦សំណើ*

*-ទទួលនូវព្រះរាជសារប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន១៣៦ព្រះរាជសារ*

*-ចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន១៣៦ព្រះរាជក្រឹត្យ ។*

**១.២.ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន** :

*-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងសម័យប្រជុំពេញអង្គវិសាមញ្ញព្រឹទ្ធសភា ចំនួន០១លើក*

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកព្រឹត្តិការណ៍* ***អង្គរសង្ក្រាន*** *ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** នៅបរិវេណមុខប្រាសាទបាយ័ន ខេត្តសៀមរាប*

*-អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាស្តីពីហេតុផលដែលនាំឲ្យមានមានការលំបាកក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ*

*-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យឆ្លង និងសម្ពោធវិមានតម្កល់រូបសំណាក់សម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត** ជោតញាណោ សម្តេចព្រះសង្ឃរាជថ្នាក់ទី១ និងសមិទ្ធផលនានាក្នុងខេត្តកំពង់ស្ពឺ*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចុះការងារមូលដ្ឋានក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-អញ្ជើញចូលសាកសួរសុខទុក្ខប្រជាពលរដ្ឋជនជាតិកួយ និងបានចូលថ្វាយបង្គំព្រះចៅអធិការវត្តអល័ង្ការ៉ាម ហៅវត្តសំអាង ក្នុងដំណើរចុះបំពេញការងារធ្វើកាត់ភូមិសាស្រ្តខេត្តស្ទឹងត្រែង ស្រុកថាឡាបរិវ៉ាត់

-អញ្ជើញចុះសួរសុខទុក្ខកុមារកំព្រានៅអង្គការបណ្តុះបណ្តាល និងថែរក្សាកុមារកំព្រា ស្ថិតនៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

-អញ្ជើញចុះសំណេះសំណាល សាកសួរសុខទុក្ខកម្មករ នៅស្ថានីយ៍ទឹកស្អាតអានកូ ដែលជារោងចក្រផលិតទឹកស្អាតសម្រាប់ផ្គត់ផ្គង់ក្រុងព្រះសីហនុ និងអញ្ជើញចូលសាកសួរសុខទុក្ខនាយទាហាន និងពលទាហាន ក្នុងទីបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង ខេត្តព្រះសីហនុ

-អញ្ជើញចុះសាកសួរសុខទុក្ខអាជ្ញាធរ សាលាស្រុកស្រែអំបិល ខេត្តកោះកុង។ ក្នុងឱកាសនោះដែរ ឯកឧត្តម បានស្តាប់របាយការណ៍ស្តីពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសភាពការណ៍អនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព ជាពិសេសក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិទើបកន្លងថ្មីៗនេះ។ ជាមួយគ្នានោះដែរ ឯកឧត្តម បានជួបសាកសួរសុខទុក្ខ និងសំណេះសំណាលជូនពរឆ្នាំថ្មីដល់ប្រជាពលរដ្ឋ នៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ផងដែរ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១២ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងសម័យប្រជុំពេញអង្គវិសាមញ្ញព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកសិក្ខាសាលាស្តីពីការផ្សព្វផ្សាយផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបិទសិក្ខាសាលាស្តីពីហេតុផលដែលនាំឲ្យមាន

ការលំបាកក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើក និងបិទវេទិកាភូមិភាគទី៣ ស្ដីពីការលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការពង្រឹងតួនាទី ភារៈកិច្ចរបស់ក្រុមប្រឹក្សា-ឃុំសង្កាត់ ក្នុងការអភិវឌ្ឍមូលដ្ឋានដោយសមភាពយេនឌ័រ នៅវត្តគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

-អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្ត និងពិធីជប់លៀងអបអរសាទរក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅវិមានព្រឹទ្ធសភា

-អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងពត្រីសមោសរអបអរសាទរសប្ដាហ៍ហ្វ្រង់កូហ្វូនី

-អញ្ជើញនាំយកទេយ្យទានប្រគេនព្រះសង្ឃគង់នៅវត្តចំនួន០៥ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ ស្ថិតក្នុងវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥១ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើកដើម្បី៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ចំនួន០៣ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គវិសាមញ្ញព្រឹទ្ធសភា៖

១.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្ដីស្នើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៣ នៃច្បាប់ស្ដីពីលក្ខន្តិកៈតំណាងរាស្ត្រ

២.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់

៣.ពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឲ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៦ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និងមាត្រា៧៤ នៃច្បាប់ស្ដីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧

៥.កំណត់កាលបរិច្ឆេទ និងរបៀបវារៈសម័យប្រជុំលើកទី៦ នីតិកាលទី៣ ។

**៣. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមេសានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៣.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងក្រុមតំណាងរាស្ត្រហត្ថលេខីរបស់រដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន០៣។

**៣.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន០៥ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០២ករណី បានទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ចំនួន០២ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន០១ករណី ព្រមទាំងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០២ករណី

-អញ្ជើញចុះបេសកកម្មទៅខេត្តព្រៃវែង ដើម្បីចុះស្រាវជ្រាវ និងប្រមូលព័ត៌មានសម្រាប់រៀបចំវេទិកាថ្នាក់ស្រុក នៅខេត្តព្រៃវែង

-ប្រជុំពិភាក្សាគម្រោងសម្រាប់សហការរៀបចំសិក្ខាសាលាស្តីពីការស្វែងយល់ និងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយរវាងព្រឹទ្ធសភា និងរដ្ឋសភា

-ប្រជុំស្តីពីការត្រៀមរៀបចំកិច្ចប្រជុំក្រុមអ្នកនយោបាយអាយ៉ាលើកទី៧

-ប្រជុំពិនិត្យ ពិភាក្សាអំពីខ្លឹមសារ និងគោលបំណងទៅធ្វើទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ នៅសាធារណរដ្ឋប្រជាមានិតចិន

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ស្តីពីគម្រោងរៀបចំវគ្គបណ្តុះបណ្តាលជូនក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តសៀមរាប

-ប្រជុំពិភាក្សាស្តីពី " ទ្រឹស្តីនៃពន្ធ " ក្រោមការឧបត្ថម្ភគាំទ្ររបស់គម្រោង GIZ

-ផ្តល់កិច្ចសម្ភាសន៍ដល់អង្គការចលនាដើម្បីសុខភាពកម្ពុជា ស្តីពីការគាំទ្រលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់

-រៀបចំវេទិកាថ្នាក់ស្រុកស្តីពី " ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ

និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាក្នុងការអភិវឌ្ឍមូលដ្ឋានដោយជានាសមភាពយេនឌ័រ "

-រៀបចំសិក្ខាសាលាស្តីពី" ហេតុផលដែលនាំឲ្យមានការលំបាកក្នុងការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ " ," គំរូ និងបែបបទនៃដំណើរការរបស់ការិយាល័យថវិកាសភា" និង "ការផ្សព្វផ្សាយផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង"

-ចូលរួមសិក្ខាសាលាស្តីពី " កិច្ចពិគ្រោះយោបល់រវាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ១" នៅខណ្ឌដង្កោ រាជធានីភ្នំពេញ

-ចូលរួមសន្និសីទស្តីពី "ការកសាងភាពជាដៃគូសម្រាប់គោលដៅអភិវឌ្ឍសហវត្សដោយចីរភាពក្រោយឆ្នាំ២០១៥"

-ចូលរួមស្តាប់បទបង្ហាញស្តីពី " បទពិសោធន៍ និងបញ្ហាប្រឈមទាក់ទងប្រព័ន្ធនិងសេវារបស់សភាស៊ុីស " និងបទបង្ហាញស្តីពី " ការស្រាវជ្រាវឯកសារជំនួយស្មារតីចំនួន៥ដើម្បីត្រៀមទស្សនកិច្ច នៅសាធារណរដ្ឋកូរ៉េ"

-ជួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារទាក់ទងទៅនឹងវិស័យជំនាញរបស់គណៈកម្មការជាមួយលោកស្រី Doris Wagner ជាសមាជិកាអចិន្ត្រៃយ៍គណបក្សបៃតងនៃប្រទេសអាល្លឺម៉ង់ ជាអ្នកនាំពាក្យផ្នែកកិច្ចការនារី និងបច្ចុប្បន្នជាអ្នកនាំពាក្យផ្នែកប្រជាសាស្ត្រនៃគណបក្សបៃតងនៅក្នុងសភា

-ជួបសំណេះសំណាលជាមួយមូលនិធិកូរ៉េ និងលោកសាស្ត្រាចារ្យ Sun JaeKim សកលវិទ្យាធិការ Batheay University មកពីខេត្តកំពង់ចាម ដើម្បីស្វែងយល់ពីសិទ្ធិសេរីភាពក្នុងសាសនា និងក្រុមបេសកកជនកូរ៉េ ដឹកនាំដោយលោក គឹម សុងតូ ដើម្បីពិភាក្សាលើកគម្រោងការងារមនុស្សធម៌

-អនុញ្ញាតឲ្យគណៈប្រតិភូយោធាភូមិភាគទី៧ កងទ័ពប្រជាជនវៀតណាម គណៈប្រតិភូបញ្ជាការសន្តិសុខជាតិតំបន់ TAY NGUYEN គណៈប្រតិភូខេត្តកនទុំ ខេត្តយ៉ាឡាយ ខេត្តអត្តាពឺ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសំណេះសំណាល និងពិភាក្សាការងារ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១៧២លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ សមា

ដឹកក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៥០លើក។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **មាន សំអាន** លោកជំទាវ **ទី ប៊ូរ៉ាស៊ី** លោកជំទាវ **ឈូក ឈឹម** លោកជំទាវ **លី នារី** ឯកឧត្តម **ម៉ម ប៊ុននាង** ឯកឧត្តម **ម៉ែន ស៊ីផាន់** ឯកឧត្តម **អន ស៊ុំ** ឯកឧត្តម **អាំ សំអាត** និងឯកឧត្តម **យូ ស៊ាងហេង** បានអញ្ជើញទៅទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ នៅខេត្តកៀងយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-ឯកឧត្តម **ម៉ុង ឫទ្ធី** អញ្ជើញចូលរួមសន្និសីទសម្រាប់សមាជិកសភាស្តីពី "**ទឹក**" នៅខេត្ត Gyeongju សាធារណរដ្ឋកូរ៉េ។

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំរវាងអាយប៉ា និងថ្នាក់ដឹកនាំអាស៊ាននាជំនួបកំពូលអាស៊ានលើកទី២៦ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំសមាជិក(APA) ក្នុងឱកាសមហាសន្និបាត (IPU) លើកទី១៣២ នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ។/.

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥

**ជ. ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន